សួស្តី! នៅក្នុងរូបភាពនេះគឺយើងនឹងនិយាយអំពីគ្រោះថ្នាក់ចរាចរណ៍
អញ្ចឹងនៅពេលដែលយើងធ្វើដំណើរតាមផ្លូវ ក៏ដូចជាតាមផ្លូវទឹក តាមផ្លូវគោក គឺ
ពេលខ្លះគឺមានគ្រោះថ្នាក់ អញ្ចឹងគ្រោះថ្នាក់នៅពេលដែលយើងធ្វើដំណើរ
យើងហៅថាគ្រោះថ្នាក់ចរាចរណ៍ យើងហៅថាគ្រោះថ្នាក់ចរាចរណ៍
ព្រោះនៅពេលដែលយើងធ្វើដំណើរនៅតាមផ្លូវ គឺយើងហៅថាធ្វើចរាចរណ៍
អញ្ចឹងនៅពេលដែលមានគ្រោះថ្នាក់ គឺយើងហៅថាគ្រោះថ្នាក់ចរាចរណ៍។

អញ្ចឹងយើងមកមើលរូបភាពទាំងអស់គ្នា នៅក្នុងរូបភាពទី ១ យើងឃើញមានបុរសវ័យក្មេងម្នាក់
ដែលគាត់មើលទៅគាត់មានវ័យប្រហែលជា ២៨ ឆ្នាំ គាត់ពាក់អាវពណ៌ស្វាយដៃខ្លី
ស្លៀកខោជើងវែងពណ៌ស អញ្ចឹងបុរសម្នាក់នោះ គាត់កំពុងតែជិះម៉ូតូ
បានន័យថាគាត់កំពុងតែបើកម៉ូតូរបស់គាត់ទៅមុខយ៉ាងលឿន អញ្ចឹងគាត់ជិះលឿន
ក៏ប៉ុន្តែម៉ូតូរបស់គាត់ យើងឃើញមានពណ៌ផ្កាឈូក មាន ម៉ូតូរបស់គាត់គឺមានពណ៌ទឹកក្រូច
ហើយម៉ូតូរបស់គាត់គឺមានកញ្ចក់សម្រាប់មើលក្រោយផងដែរ
អញ្ចឹងបានន័យថានៅពេលដែលគាត់ជិះម៉ូតូ គាត់អត់ចាំបាច់ងាកក្រោយទេ
គាត់អត់ចាំបាច់ងាកក្រោយទេ គឺគាត់គ្រាន់តែមើលតាមកញ្ចក់
គឺគាត់មើលដឹងថាតើមានអ្វីនៅខាងក្រោយគាត់ ឬក៏នៅពេលដែលគាត់ចង់បត់ឆ្វេង ឬក៏បត់ស្តាំ
គាត់អាចមើលកញ្ចក់ដែលនៅក្បែរចង្កូតម៉ូតូបាន អញ្ចឹងគាត់អត់ចាំបាច់ងាកក្រោយទេ
ព្រោះថាការងាកក្រោយ នៅពេលដែលយើងជិះម៉ូតូ គឺវាអាចបង្កឲ្យយើងមានគ្រោះថ្នាក់បាន
គឺវាគ្រោះថ្នាក់ខ្លាំងណាស់ ព្រោះពេលខ្លះ នៅពេលដែលយើងងាកក្រោយ
គឺយើងអត់អាចឃើញអ្វីនៅខាងមុខនោះទេ ដូច្នេះយើងអាចរេចង្កូតម៉ូតូទៅប៉ះអ្នកដទៃ
ឬក៏ទៅប៉ះម៉ូតូផ្សេងទៀត ឬក៏ទៅប៉ះឡាន ឬក៏ទៅប៉ះឡានដែលធ្វើដំណើរស្របទិសគ្នា
អញ្ចឹងយើងអាចប៉ះឡានដែលធ្វើដំណើរស្របទិសគ្នាបាន ដូច្នេះយើង[មើល]គ្រាន់តែមើលកញ្ចក់
វាងាយស្រួលជាងការងាកមើលខាងក្រោយ ព្រោះវាអាចកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍បាន។
អញ្ចឹងបុរសម្នាក់ហ្នឹង គាត់ពាក់មួកសុវត្ថិភាពការពារក្បាលរបស់គាត់ផងដែរ
អញ្ចឹងជាទូទៅការពាក់មួកសុវត្ថិភាព គឺអាចការពារក្បាលរបស់យើង
នៅពេលដែលយើងគ្រោះថ្នាក់ចរាចរណ៍ ហើយម្យ៉ាងវិញទៀត
ប្រសិនបើយើងជិះម៉ូតូអត់ពាក់មួកសុវត្ថិភាពទេ នោះប៉ូលិសនឹងផាកយើងជាមិនខាន
ដោយសារតែវាខុសទៅនឹងច្បាប់ចរាចរណ៍ អញ្ចឹងនៅពេលដែលយើងជិះម៉ូតូ
យើងត្រូវមានកញ្ចក់មើលក្រោយនិងពាក់មួកសុវត្ថិភាពឲ្យជាប់ជានិច្ច ដើម្បីការពារសុវត្ថិភាពផង
និងដើម្បីគោរពច្បាប់ចរាចរណ៍ផង ក៏ប៉ុន្តែនៅក្នុងរូបភាពនេះ គឺបុរសម្នាក់នេះ គាត់
ប្រហែលជាគាត់ប្រញាប់ទៅកន្លែងណាមួយ អាចគាត់ណាត់ជាមួយនឹងមិត្តភក្តិរបស់គាត់

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដើម្បីទៅកន្លែងនិយាយគ្នាលេង ឬក៏គាត់ប្រញាប់ទៅកន្លែងណាមួយ
អញ្ចឹងយើងឃើញគាត់ជិះម៉ូតូយ៉ាងលឿន ដែលការជិះម៉ូតូលឿនគឺវាអត់មានសុវត្ថិភាពទេ
គឺវាងាយនឹងបង្កគ្រោះថ្នាក់ចរាចរណ៍ខ្លាំងណាស់ អញ្ចឹងប្រសិនបើយើងធ្វើដំណើរ
យើងត្រូវធ្វើដំណើរដោយល្មមៗ ដោយមិនត្រូវបើកលឿនពេក ឬក៏មិនត្រូវបើកយឺតពេកនោះទេ
ព្រោះនៅពេលដែលយើងបើកលឿនពេក វាងាយស្រួលនឹងគ្រោះថ្នាក់ចរាចរណ៍
ក៏ប៉ុន្តែប្រសិនបើយើងបើកយឺតពេក វាអាចធ្វើឲ្យស្ទះចរាចរណ៍បាន
បានន័យថាអ្នកដទៃដែលនៅពីក្រោយ គឺគាត់អត់អាចទៅមុខបានលឿន
ដូច្នេះវាធ្វើឲ្យស្ទះចរាចរណ៍គេនៅខាងក្រោយ។

បន្ទាប់មកទៀតរូបភាពទី ២ រូបភាពទី ២ យើងឃើញបុរសដែលគាត់ជិះម៉ូតូលឿនអម្បាញ់មិញ
គឺគាត់ជិះម៉ូតូ ប្រហែលជាគាត់មានណាត់ទៅជាមួយនឹងមិត្តភក្តិរបស់គាត់ទៅឆ្ងាយ
ហើយប្រហែលជាគាត់ទៅយឺតម៉ោង ដូច្នេះគាត់ជិះយ៉ាងលឿន
អញ្ចឹងនៅពេលដែលគាត់ជិះម៉ូតូលឿន ដោយសារតែផ្លូវមានទឹក ប្រហែលជានៅក្នុងថ្ងៃនេះ
គឺទើបតែមេឃរាំងភ្លៀងហើយ អញ្ចឹងអាចនឹងមេឃទើបតែរាំងភ្លៀង
ដូច្នេះធ្វើឲ្យមានទឹកដក់នៅតាមផ្លូវ អញ្ចឹងនៅពេលដែលទឹកដក់នៅតាមផ្លូវ
គឺវាងាយស្រួលនឹងបង្កគ្រោះថ្នាក់ខ្លាំងណាស់ ដោយសារតែពេលខ្លះ នៅពេលដែលមានទឹកដក់
យើងអត់អាចមើលឃើញក្រឡុក ឬក៏យើងអត់អាចដឹងថាមានក្រឡុកធំ ឬក៏តូចនៅតាមផ្លូវនោះទេ
ដោយសារតែមានទឹកយើងមើលអត់ឃើញ ដូច្នេះវានឹងអាចបង្កគ្រោះថ្នាក់បាន
ប្រសិនបើយើងជិះទៅប៉ះក្រឡុកឬក៏រអិលនៅលើផ្លូវទឹកនោះ ព្រោះប្រសិនបើអត់មានក្រឡុក
ឬក៏អត់មានក្រឡុកទេ ពេលផ្លូវដក់ទឹកគឺអាចធ្វើឲ្យផ្លូវរអិល ដូច្នេះវាពិបាកនៅក្នុងការធ្វើដំណើរ
ប្រសិនបើយើងជិះមិនប្រុងប្រយ័ត្ន គឺវាអាចធ្វើឲ្យកង់ឡាន ឬក៏កង់ម៉ូតូរបស់យើងហ្នឹង
ងាយស្រួលនឹងរអិលចេញពីផ្លូវ ហើយប្រសិនបើយើងជិះឡាន
គឺអាចធ្វើឲ្យយើងរេចង្កូតឡានទៅឆ្វេងឬក៏ទៅស្តាំ អាចប៉ះពាល់ដល់អ្នកដទៃ
ហើយប្រសិនបើយើងជិះម៉ូតូ វាអាចធ្វើឲ្យយើងរអិលម៉ូតូដួលបាន អញ្ចឹងនៅក្នុងរូបភាពទី ២ នេះ
គឺបុរសម្នាក់នោះ គាត់បានជិះម៉ូតូកិនផ្លូវដែលមានទឹកដក់
ដូច្នេះយើងឃើញថាគាត់រអិលម៉ូតូរបស់គាត់ កង់ខាងមុខរបស់គាត់បានកិនលើទឹក
អញ្ចឹងម៉ូតូមានកង់ពីរ គឺកង់ខាងមុខមួយ និងកង់ខាងក្រោយមួយ អញ្ចឹងនៅក្នុងរូបភាពហ្នឹង
យើងឃើញបុរសម្នាក់នោះ គាត់ កង់ខាងមុខរបស់គាត់ កង់ម៉ូតូខាងមុខរបស់គាត់
គឺកិនផ្លូវដែលមានទឹកដក់ ដូច្នេះធ្វើឲ្យវារអិល ដោយសារតែគាត់ជិះលឿនផង
អញ្ចឹងដោយសារតែគាត់បើកបរនៅក្នុងល្បឿនលឿន នៅក្នុងល្បឿនលឿន
ដូច្នេះវាធ្វើឲ្យគាត់នៅពេលដែលគាត់ប៉ះផ្លូវរអិលគឺវាពិបាកនឹងទប់ចង្កូត

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងយើងឃើញនៅក្នុងរូបភាពនេះ គឺគាត់កំពុងតែព្យាយាមទប់ចង្កូតរបស់គាត់ដែលរអិល
ព្រោះគាត់កិននៅលើទឹក ដូច្នេះវារអិលចង្កូតធ្វើឲ្យរេចង្កូត អញ្ចឹងប្រសិនបើគាត់ទប់ចង្កូតអត់នឹងទេ
គឺវាអាចធ្វើឲ្យគាត់មានគ្រោះថ្នាក់បាន គឺវាអាចធ្វើឲ្យគាត់ដួលបាន អញ្ចឹងបុរសម្នាក់នេះ
នៅក្នុងរូបភាពទី ២ គឺគាត់កំពុងតែព្យាយាមទប់ចង្កូតម៉ូតូរបស់គាត់កុំឲ្យដួល
ឬក៏កុំឲ្យរអិលនៅពេលដែលគាត់ជិះនៅលើផ្លូវដែលមានទឹកដក់ ដោយសារតែថ្ងៃនេះ
ប្រហែលជាមានភ្លៀងធ្លាក់ ឬក៏ប្រហែលជាទើបតែរាំងភ្លៀង ដូច្នេះធ្វើឲ្យមានទឹកដក់នៅតាមផ្លូវ
ដែលជាហេតុងាយបង្កឲ្យមានគ្រោះថ្នាក់ចរាចរណ៍។

បន្ទាប់មករូបភាពទី ៣ រូបភាពទី ៣ យើងឃើញថា បុរសម្នាក់នោះ គាត់
ទោះបីជាគាត់ព្យាយាមទប់ចង្កូតរបស់គាត់កុំឲ្យរអិលយ៉ាងណាក៏ដោយ
ក៏ប៉ុន្តែដោយសារតែគាត់ជិះលឿនពេក ដោយសារតែគាត់បើកបរក្នុងល្បឿនលឿនពេក
ដូច្នេះនៅពេលដែលគាត់កិនផ្លូវរអិល ជិះកាត់ផ្លូវរអិល ឬក៏ជិះកាត់ទឹក
អញ្ចឹងវាធ្វើឲ្យគាត់ទប់ចង្កូតអត់ជាប់ ដូច្នេះនៅក្នុងរូបភាពទី ៣ យើងឃើញថា
ម៉ូតូរបស់គាត់ក៏បានដួល អញ្ចឹងប្រសិនបើយើងជិះយឺតៗ ឬក៏ជិះល្មមៗ
គឺនៅពេលដែលយើងជិះកាត់ផ្លូវរអិល ឬក៏ជិះកាត់ក្រឡុក ឬក៏ជិះកាត់ទឹកដក់
គឺយើងអាចទប់ចង្កូតបាន បានន័យថាយើងអាចទប់លំនឹងម៉ូតូរបស់យើងមិនឲ្យរេ
ឬក៏មិនឲ្យរអិលដួលបាន ឬក៏យើងអាចដាក់ជើងទប់ជាប់បាន
បានន័យថាយើងគ្រាន់តែដាក់ជើងដាក់ចុះមកដី គឺវាអាចទប់លំនឹងម៉ូតូរបស់យើងកុំឲ្យដួលបាន
ក៏ប៉ុន្តែប្រសិនបើយើងជិះលឿនពេក ប្រសិនបើយើងជិះលឿនពេក នៅពេលដែលម៉ូតូរអិល
គឺយើងអត់អាចទប់ជាប់នោះទេ បានន័យថាម៉ូតូរបស់យើងនឹងអាចដួលបាន
ព្រោះនៅពេលដែលយើងជិះលឿនគឺល្បឿនម៉ូតូនឹងធ្វើឲ្យម៉ូតូរអិលខ្លាំង
ដូច្នេះយើងអត់អាចទប់ជាប់នោះទេ ដោយជាក់ស្តែងនៅក្នុងរូបភាពទី ៣ នេះ បុរសម្នាក់នោះ
គាត់អត់អាចទប់ល្បឿនម៉ូតូរបស់គាត់ជាប់ អញ្ចឹងនៅពេលដែលគាត់ជិះកាត់ផ្លូវរអិល
ពេលដែលគាត់ជិះកាត់ផ្លូវរអិលធ្វើឲ្យម៉ូតូគាត់ដួល អញ្ចឹងយើងឃើញគាត់ខ្ទាតចេញពីម៉ូតូ
ដោយសារតែគាត់ជិះលឿន ដូច្នេះនៅពេលដែលម៉ូតូដួលធ្វើឲ្យគាត់ខ្ទាតចេញពីម៉ូតូ
ហើយដួលបោកទៅនឹងថ្នល់ អញ្ចឹងដោយសារតែគាត់ពាក់មួកការពារសុវត្ថិភាព
ដូច្នេះក្បាលរបស់គាត់ប្រហែលជាអត់មានបញ្ហានោះទេ ក៏ប៉ុន្តែខ្លួនរបស់គាត់ប្រហែលជាមានបញ្ហា
ដោយសារតែយើងឃើញនៅទីនេះ គឺគាត់កំពុងតែខ្ទាតចេញពីម៉ូតូដែលគាត់កំពុងតែជិះ
ដោយសារតែគាត់រអិលដួល ដោយសារតែម៉ូតូរបស់គាត់កិនទៅលើផ្លូវរអិល
ហើយម៉ូតូរបស់គាត់បានដួល និងដោយសារតែគាត់ជិះក្នុងល្បឿនលឿនផង

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដូច្នេះនៅពេលដែលម៉ូតូគាត់ដួល ធ្វើឲ្យគាត់ខ្ទាតចេញពីម៉ូតូយ៉ាងឆ្ងាយ
ហើយម៉ូតូរបស់គាត់អូសលើផ្លូវយ៉ាងឆ្ងាយផងដែរ។

បន្ទាប់មកទៀតរូបភាពទី ៤ នៅក្នុងរូបភាពទី ៤ យើងឃើញថា បុរសម្នាក់នោះ គាត់បានដួលម៉ូតូ
បន្ទាប់មកយើងឃើញគាត់ខ្ទាតពីលើម៉ូតូហើយមកដេកទៅនឹងថ្នល់
អញ្ចឹងដោយសារតែគាត់ខ្ទាតចេញពីម៉ូតូ ដូច្នេះខ្លួនរបស់គាត់បានបោកទៅនឹងថ្នល់
អញ្ចឹងធ្វើឲ្យគាត់មានការឈឺចាប់នៅលើខ្លួន នៅលើដៃ នៅលើជើងគាត់យ៉ាងខ្លាំង
ក៏ប៉ុន្តែក្បាលរបស់គាត់ ដោយសារតែគាត់ពាក់មួកសុវត្ថិភាពការពារ
ដូច្នេះគាត់មិនមានគ្រោះថ្នាក់ក្បាលនោះទេ អញ្ចឹងគាត់គ្រាន់តែឈឺខ្លួន ឈឺគ្រោះថ្នាក់ចំដៃ
ចំជើងតែប៉ុណ្ណោះ ក៏ប៉ុន្តែក្បាលរបស់គាត់គឺមានសុវត្ថិភាពដោយសារតែគាត់ពាក់មួកសុវត្ថិភាព
អញ្ចឹងប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែគាត់ជិះម៉ូតូលឿន
ហើយដោយសារតែម៉ូតូគាត់ដួល គាត់ដួលបោកទៅនឹងថ្នល់ ដូច្នេះគាត់អត់អាចងើបរួចនោះទេ
ដោយសារតែគាត់មានអារម្មណ៍ថាឈឺចាប់ខ្លាំង ដោយសារតែគាត់បោកទៅនឹងថ្នល់
ព្រោះពេលខ្លះថ្នល់កៅស៊ូ ឬក៏ថ្នល់បេតុង យើងចាក់ស៊ីម៉ងត៍បេតុង
អញ្ចឹងធ្វើឲ្យនៅពេលដែលយើងប៉ះទង្គិចខ្លាំង គឺវាធ្វើឲ្យខ្លួនយើងដួលហើយនិងឈឺ
ហើយពេលខ្លះវាអាចយើងគ្រាំគ្រា ឬក៏គ្រាំខ្នងបាន ដូច្នេះយើងឃើញនៅក្នុងរូបភាពនេះ
គឺបុរសម្នាក់នោះ បន្ទាប់ពីគាត់ដួលម៉ូតូ គឺគាត់ងើបអត់រួចនោះទេ គឺគាត់បានដេកនៅនឹងថ្នល់
នៅកន្លែងដែលគាត់ដួលម៉ូតូនោះ នៅកន្លែងដែលគាត់ខ្ទាតចេញពីម៉ូតូ
អញ្ចឹងយើងឃើញមានអ្នកដំណើរផ្សេងទៀត ដែលគាត់កំពុងតែដើរនៅតាមផ្លូវ
គឺគាត់ភ្ញាក់ផ្អើលយ៉ាងខ្លាំង ដែលយើងឃើញនៅក្បែរបុរសម្នាក់នោះ គឺមាននារីម្នាក់
ដែលគាត់ស្លៀកសំពត់ពណ៌ខៀវ ពាក់អាវដៃខ្លីពណ៌ស និងមានពាក់វ៉ែនតាផងដែរ
នារីម្នាក់នោះគឺមានសក់ខ្លី ហើយគាត់ភ្ញាក់ផ្អើលយ៉ាងខ្លាំង ដែលគាត់កំពុងតែរត់មកមើល
ឬក៏រត់មកជួយបុរសម្នាក់នោះ ដែលនៅខាងក្រោយនារីម្នាក់នោះគឺមានមនុស្សប្រុសស្រីផ្សេងទៀត
ដែលកំពុងតែរត់មកជួយដែរ បានន័យថានៅពេលដែលយើងឃើញមនុស្សគ្រោះថ្នាក់ចរាចរណ៍
ជាទូទៅមនុស្សដែលនៅក្បែរៗនោះ គាត់តែងតែរត់មកជួយ
គាត់រត់មកមើលថាតើគ្រោះថ្នាក់ចរាចរណ៍នោះខ្លាំងដែរឬទេ
ហើយប្រសិនបើខ្លាំងគឺគាត់នឹងតេហៅឡានពេទ្យ ហើយប្រសិនបើមិនខ្លាំងទេ
គឺយើងអាចព្យាបាលខ្លួនឯងបាន អញ្ចឹងពួកគាត់ អ្នកដែលនៅក្បែរកន្លែងកើតហេតុ
គាត់តែងតែមកមើលជនរងគ្រោះនិងជួយជនរងគ្រោះទៅតាមលទ្ធភាពរបស់គាត់។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ៥ រូបភាពទី ៥ បន្ទាប់ពីរត់មកមើលជនរងគ្រោះហើយ នារីម្នាក់នោះ
គាត់ក៏សម្រេចចិត្តតែទៅកាន់ឡានពេទ្យ អញ្ចឹងពេលខ្លះ នៅពេលដែលមានគ្រោះថ្នាក់ចរាចរណ៍
អ្នកដែលនៅជិតខាង ឬអ្នកដែលនៅកន្លែងកើតហេតុ
គាត់រត់មកមើលជនរងគ្រោះថាតើជនរងគ្រោះរបួសធ្ងន់ឬទេ
អញ្ចឹងពេលខ្លះប្រសិនបើរបួសគាត់គ្រាន់តែរបួសស្រាល
បានន័យថារបួសស្រាលគឺគាត់របួសអត់ធ្ងន់ធ្ងរទេ គឺរបួសគាត់ត្រឹមតែរលាត់ដៃ រលាត់ជើង
ឬក៏រលាត់ស្បែកតែប៉ុណ្ណោះ អញ្ចឹងគាត់អាចលាបថ្នាំ ឬក៏យកថ្នាំទៅលេបគឺអាចជាសះស្បើយ
ដូច្នេះគាត់អត់ចាំបាច់ទៅពេទ្យទេ ដោយសារតែគាត់មានរបួសស្រាល ក៏ប៉ុន្តែអ្នកខ្លះទៀត គាត់
នៅពេលដែលគាត់គ្រោះថ្នាក់ចរាចរណ៍គឺគាត់របួសធ្ងន់ ដូចជាដោយសារតែគាត់ជិះលឿន
ឬក៏ដោយសារតែគ្រោះថ្នាក់ចរាចរណ៍នោះគឺធ្ងន់ធ្ងរ ដូច្នេះអ្នកខ្លះគាត់អាចបាក់ដៃ បាក់ជើង
អ្នកខ្លះគាត់អាចបែកក្បាល ឬក៏អ្នកខ្លះគាត់អាចសន្លប់ អញ្ចឹងនៅពេលដែលមានរបួសធ្ងន់ធ្ងរ
អ្នកដែលនៅកន្លែងកើតហេតុ ឬក៏អ្នកដែលនៅក្បែរៗនោះ
គាត់តែងតែតែទៅហៅឡានពេទ្យឲ្យមកជួយសង្គ្រោះ ព្រោះថាប្រសិនបើអត់ហៅឡានពេទ្យទេ
គាត់អាចនឹងមានគ្រោះថ្នាក់ដល់ជីវិតបាន អញ្ចឹងប្រសិនបើគាត់មានរបួសស្រាល
គឺយើងអត់ចាំបាច់ហៅឡានពេទ្យទេ គឺយើងគ្រាន់តែអាចទៅពេទ្យដោយខ្លួនឯង
ឬក៏ទៅគ្លីនិកដែលនៅជិតៗនោះ ដើម្បីទិញថ្នាំ ឬក៏ដើម្បីលាងរបួសជាការស្រេច
ដោយយើងអត់ចាំបាច់ទៅពេទ្យទេ ក៏ប៉ុន្តែប្រសិនបើខ្លាំង គឺយើងត្រូវទៅពេទ្យ
ដែលមានឡានពេទ្យមកជំនួយ ដែលជាក់ស្តែងនៅក្នុងរូបភាពនេះ គឺបុរសម្នាក់នោះ
គាត់មានគ្រោះថ្នាក់ចរាចរណ៍ដែលមានរបួសធ្ងន់ ដូច្នេះអ្នកដែលនៅក្បែរនោះ
ដែលជានារីម្នាក់ដែលពាក់អាវសដៃខ្លី និងមានពាក់វ៉ែនតានោះ
គាត់បានសម្រេចចិត្តតែហៅឡានពេទ្យ ដើម្បីមកជួយសង្គ្រោះគាត់ឲ្យផុតពីគ្រោះថ្នាក់ដល់ជីវិត។

បន្ទាប់មករូបភាពទី ៦ រូបភាពទី ៦ យើងឃើញមានឡានពេទ្យមួយកំពុងតែបើកបរ
អញ្ចឹងឡានពេទ្យ បន្ទាប់ពីបានទទួលព័ត៌មាន
ឬក៏ទទួលទូរស័ព្ទរបស់នារីម្នាក់តែប្រាប់គាត់អំពីគ្រោះថ្នាក់ចរាចរណ៍មួយនោះហើយ
អញ្ចឹងឡានពេទ្យគាត់ក៏មក ជិះសំដៅមករកកន្លែងកើតហេតុ ដើម្បីជួយសង្គ្រោះបុរសម្នាក់នោះ
អញ្ចឹងជាទូទៅឡានពេទ្យគឺខុសពីឡានយើងធម្មតា ដោយសារតែឡានយើងធម្មតា
យើងតែងតែជិះក្នុងល្បឿនធម្មតា ក៏ប៉ុន្តែឡានពេទ្យគឺយើងឃើញមានបិទសញ្ញាបូកនៅលើទ្វារ
នៅលើកញ្ចក់ឡានពេទ្យទាំងអស់ ដើម្បីបញ្ជាក់ថាគឺជាឡានពេទ្យ
ហើយម្យ៉ាងវិញទៀតឡានពេទ្យគឺមាន តែងតែមានភ្លើងស៊ីរ៉ែន យើងហៅថាភ្លើងស៊ីរ៉ែន
ដើម្បីបន្លឺសំឡេងផង និងដើម្បីបញ្ចេញភ្លើង សុំផ្លូវផង

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដោយសារតែឡានពេទ្យគឺប្រញាប់ទៅជួយសង្គ្រោះអ្នកដទៃដែលមានគ្រោះថ្នាក់
ឬក៏ជួយសង្គ្រោះអ្នកជំងឺ ដូច្នេះឡានពេទ្យគឺមានអាទិភាព
បានន័យថានៅពេលដែលគាត់ធ្វើដំណើរនៅលើផ្លូវ ឬក៏ធ្វើចរាចរណ៍នៅលើផ្លូវ
គឺអ្នកទាំងអស់គ្នាដែលជិះនៅខាងមុខឡានពេទ្យ គឺត្រូវតែចៀសផ្លូវឲ្យឡានពេទ្យទៅមុន
គឺឡានពេទ្យគាត់បានបញ្ចេញស៊ីរ៉ែន និងបញ្ចេញភ្លើងស៊ីញ៉ូ ដើម្បីសុំផ្លូវបានទៅមុន
ព្រោះថាគាត់ប្រញាប់ទៅជួយសង្គ្រោះអ្នកជំងឺ អញ្ចឹងនៅពេលដែលយើងឃើញឡានពេទ្យ
យើងអត់ត្រូវបើកបរនៅខាងមុខឡានពេទ្យនោះទេ ព្រោះវាអាចធ្វើឲ្យយើងមានគ្រោះថ្នាក់បាន
ដោយសារតែឡានពេទ្យបើកនៅក្នុងល្បឿនលឿន ដូច្នេះនៅពេលដែលយើងឮសូរសំឡេងឡានពេទ្យ
ឬក៏ឮស៊ីរ៉ែនឡានពេទ្យ យើងត្រូវចៀសមកខាងចិញ្ចើមផ្លូវ ដើម្បីទុកកណ្ដាលផ្លូវ ផ្លូវទ្រូងផ្លូវ
ឲ្យឡានពេទ្យបើកបរ ព្រោះគាត់ប្រញាប់ទៅជួយសង្គ្រោះគេ អញ្ចឹងឡានពេទ្យ
នៅពេលដែលប្រញាប់ទៅជួយសង្គ្រោះ គឺតែងតែបើកភ្លើងស៊ីរ៉ែន និងបើកភ្លើងស៊ីញ៉ូ
ដើម្បីសុំផ្លូវជានិច្ច។

បន្ទាប់មកទៀតរូបភាពទី ៧ នៅក្នុងរូបភាពទី ៧ យើងឃើញក្រុមសង្គ្រោះបឋមរបស់គ្រូពេទ្យ
អញ្ចឹងក្រុមគ្រូពេទ្យគាត់បានមកដល់កន្លែងកើតហេតុ ហើយមកមើលបុរសម្នាក់នោះ
អញ្ចឹងយើងឃើញមានពេទ្យចំនួនពីរនាក់ ពេទ្យចំនួនពីរនាក់
ដែលគាត់ស្លៀកពាក់ឯកសណ្ឋានជាពេទ្យ គឺពាក់អាវស ខោស និងមានចងបូរសញ្ញារូបពេទ្យ
ឬគឺសញ្ញាបូកលេខពណ៌ក្រហម សញ្ញាបូកពណ៌ក្រហមនៅនឹងដៃស្ដាំរបស់គាត់
ហើយគាត់បានទៅត្រួតពិនិត្យទៅលើបុរសដែលគ្រោះថ្នាក់ចរាចរណ៍នោះផងដែរ
អញ្ចឹងគាត់បានស្ទាបនឹងបានលើកបុរសដែលមានគ្រោះថ្នាក់នោះមកដាក់នៅលើគ្រែរុញកាមួយ
អញ្ចឹងគាត់នាំគ្នាសែងបុរសម្នាក់នោះ ប៉ុន្តែដោយសារបុរសម្នាក់នោះ
គាត់មានគ្រោះថ្នាក់ចរាចរណ៍ដែលប៉ះពាល់ទៅនឹងជើង និងដៃ និងគាត់ឈឺខ្លួន
ដោយសារតែគាត់បោកទៅនឹងថ្នល់ខ្លាំងពេក អញ្ចឹងនៅពេលដែលគាត់ដួល
គាត់បោកទៅនឹងថ្នល់ខ្លាំង ដូច្នេះបានធ្វើឲ្យគាត់ឈឺយ៉ាងខ្លាំង
អញ្ចឹងនៅពេលដែលពេទ្យគាត់លើកបុរសម្នាក់នោះដាក់ហ្វ្រង់កា គឺធ្វើឲ្យគាត់ឈឺ និងស្រែកយ៉ាងខ្លាំង
ដោយសារតែគាត់មានរបួស ដូច្នេះពេទ្យនឹងព្យាយាមលើកថ្នមៗ ដើម្បីកុំឲ្យរបួសកាន់តែធ្ងន់ធ្ងរ
ដោយសារតែបុរសម្នាក់នោះគាត់ងើបអត់រួច
ដោយសារតែបុរសម្នាក់នោះគាត់ងើបដើរអត់រួចដោយខ្លួនឯង
ដូច្នេះពេទ្យត្រូវសែងគាត់ដោយប្រើប្រាស់ហ្វ្រង់កា
អញ្ចឹងពេទ្យជាដំបូងគាត់លើកបុរសម្នាក់នោះពីថ្នល់ ហើយដាក់នៅលើហ្វ្រង់កា
ដើម្បីសែងដាក់ចូលឡានពេទ្យ។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ៨ នៅក្នុងរូបភាពទី ៨ យើងឃើញថា ដោយសារតែបុរសម្នាក់នោះ
គាត់ដើរអត់រួច ដូច្នេះពេទ្យក៏ចាប់ផ្ដើមសែងគាត់ដាក់លើប្រៀងកា
នៅពេលដែលគាត់ដាក់លើប្រៀងការួចរាល់ហើយ អញ្ចឹងពេទ្យទាំងពីរនាក់ លោកគ្រូពេទ្យទាំងពីរនាក់
ក៏បានសែងបុរសនោះចូលទៅក្នុងឡានពេទ្យ ដោយសារតែមានការប្រុងប្រយ័ត្ន
ដើម្បីកុំឲ្យអ្នកជំងឺធ្លាក់ពីលើប្រៀងកា ដូច្នេះប្រៀងកានីមួយៗតែងតែមានខ្សែក្រវាត់រឹតអ្នកជំងឺកុំឲ្យធ្លាក់
ព្រោះដោយសារតែប្រៀងកាគឺជាក្រណាត់មួយផ្ទាំង ដែលយើងដាក់ដែក ឬក៏ដាក់ឈើនៅសងខាង
ហើយដាក់អ្នកជំងឺនៅលើក្រណាត់នោះដើម្បីសែង អញ្ចឹងវាអត់មានជញ្ជាំង
ដើម្បីទប់អ្នកជំងឺកុំឲ្យធ្លាក់នោះទេ ដូច្នេះដើម្បីធានាសុវត្ថិភាពអ្នកជំងឺកុំឲ្យធ្លាក់ពីលើប្រៀងកា
យើងត្រូវរុំខ្សែក្រវាត់អ្នកជំងឺឲ្យជាប់ដើម្បីកុំឲ្យគាត់ធ្លាក់ ព្រោះដោយសារតែគាត់កំពុងតែមានរបួស
ដូច្នេះប្រសិនបើគាត់ធ្លាក់គឺអាចធ្វើឲ្យរបួសគាត់កាន់តែធ្ងន់ធ្ងរបាន
អញ្ចឹងគ្រូពេទ្យត្រូវតែមានការប្រុងប្រយ័ត្នជានិច្ច។ នៅក្នុងរូបភាពទី ៨ យើងឃើញ
គ្រូពេទ្យសែងបុរសម្នាក់នោះចូលទៅក្នុងឡានពេទ្យ ដោយចូលទៅតាមទ្វារចំហៀង
អញ្ចឹងឡានពេទ្យគឺមានទ្វារច្រើន គឺមានទ្វារកន្លែងអ្នកបើកបរចំនួនពីរ ទ្វារចំហៀងចំនួនមួយ
សម្រាប់លើកអ្នកជំងឺចូល និងទ្វារខាងក្រោយចំនួនមួយផងដែរ
ព្រោះប្រសិនបើអ្នកជំងឺគាត់ធ្ងន់ធ្ងរខ្លាំង គឺសែងអត់បាន គឺប្រើប្រៀងការុញ
ដូច្នេះប្រសិនបើគេប្រើប្រៀងការុញ គឺគេចូលតាមទ្វារខាងក្រោយនៃឡាន
ប៉ុន្តែប្រសិនបើគេប្រើប្រៀងកាសែង គឺគេចូលតាមទ្វារចំហៀង ដូច្នេះពេទ្យគាត់បានបើកទ្វារចំហៀង
ដើម្បីសែងបុរសម្នាក់នោះចូលទៅក្នុងឡាន។

បន្ទាប់មកទៀតរូបភាពទី ៩ នៅក្នុងរូបភាពទី ៩ យើងឃើញថា
បន្តិចក្រោយមកឡានពេទ្យក៏បានមកដល់មន្ទីរពេទ្យ
អញ្ចឹងបន្ទាប់ពីឡានពេទ្យគាត់បានទៅជួយសង្គ្រោះ និងបានទៅយកអ្នកជំងឺពីកន្លែងកើតហេតុ
ឬក៏កន្លែងគ្រោះថ្នាក់ចរាចរណ៍ហើយ អញ្ចឹងឡានពេទ្យគាត់បើកត្រលប់មកពេទ្យវិញ
ដោយសារតែនៅមន្ទីរពេទ្យគឺមានច្រកពីរ បានន័យថានៅពេលដែលអ្នកមានជំងឺធ្ងន់ធ្ងរ
ឬក៏អ្នកដែលត្រូវសង្គ្រោះបន្ទាន់ គេឲ្យច្រក]ចូលច្រកផ្សេង គឺច្រកសង្គ្រោះបន្ទាន់
ចំណែកឯអ្នកជំងឺធម្មតា គឺចូលទៅក្នុងច្រកអ្នកជំងឺធម្មតា ព្រោះថាអ្នកដែលឈឺធ្ងន់ធ្ងរ
គឺត្រូវសង្គ្រោះបន្ទាន់ ដោយសារតែមានការប្រញាប់ ដូច្នេះមានការប្រញាប់ជាងអ្នកជំងឺធម្មតា
ប្រសិនបើគាត់ចូលច្រកជំងឺធម្មតា គឺអាចធ្វើឲ្យគាត់មានការព្យាបាលយឺតយ៉ាវ
ដូច្នេះអាចធ្វើឲ្យគាត់មានគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬក៏អាចគ្រោះថ្នាក់ដល់ជីវិត អញ្ចឹងប្រសិនបើគាត់ធ្ងន់ធ្ងរ
គឺគេចូលច្រកអ្នកជំងឺធ្ងន់ធ្ងរដែលចូលទៅច្រកសង្គ្រោះបន្ទាន់

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដើម្បីឲ្យក្រុមគ្រូពេទ្យធ្វើការជួយសង្គ្រោះពួកគាត់បានទាន់ពេលវេលា
ចំណែកឯអ្នកដែលមានជំងឺធម្មតា ឬក៏ជំងឺស្រាល
គឺយើងអត់ចាំបាច់ចូលទៅក្នុងច្រកអ្នកជំងឺសង្គ្រោះបន្ទាន់ទេ គឺយើងចូលច្រកធម្មតា
ហើយយើងអាចចាប់លេខ ឬក៏ធ្វើទៅតាមនីតិវិធីរបស់ពេទ្យ ដើម្បីព្យាបាលជំងឺធម្មតារបស់យើង
ប៉ុន្តែប្រសិនបើអ្នកមានជំងឺធ្ងន់ធ្ងរ គឺគេចូលទៅច្រកអ្នកជំងឺសង្គ្រោះបន្ទាន់ អញ្ចឹងបុរសម្នាក់នេះ
គាត់ប្រហែលជាធ្ងន់ធ្ងរដោយសារតែគាត់គ្រោះថ្នាក់ចរាចរណ៍ខ្លាំង
ដូច្នេះឡានពេទ្យក៏បានដឹកជញ្ជូនគាត់ចូលទៅក្នុងកន្លែងអ្នកជំងឺដែលត្រូវសង្គ្រោះបន្ទាន់
អញ្ចឹងឡានពេទ្យបានឈប់ទៅនឹងខ្លោងទ្វារ ឈប់ខាងមុខខ្លោងទ្វារមន្ទីរពេទ្យ ដើម្បីដាក់អ្នកជំងឺចុះ
ដោយយើងឃើញនៅទីនេះ គឺមានខ្លោងទ្វារចំនួនពីរ ហើយទ្វារគឺជាទ្វារកញ្ចក់
ដែលយើងឃើញនៅសងខាងផ្លូវគឺមានសញ្ញាបូក អញ្ចឹងសញ្ញាបូកគឺជាសញ្ញាពេទ្យ
បានន័យថានៅពេលដែលយើងទៅពេទ្យ យើងតែងតែឃើញមានសញ្ញាបូកមួយ ព្រោះសញ្ញាបូកនេះ
គឺតំណាងឲ្យសញ្ញាពេទ្យ អញ្ចឹងបុរសម្នាក់នោះត្រូវបានដឹកជញ្ជូនតាមរយៈឡានពេទ្យ
មកដល់មន្ទីរពេទ្យ ដើម្បីសង្គ្រោះបន្ទាន់។

បន្ទាប់មកទៀតរូបភាពទី ១០ នៅក្នុងរូបភាពទី ១០ យើងឃើញថា
បន្ទាប់ពីបុរសម្នាក់នោះមកដល់មន្ទីរពេទ្យហើយ
ក្រុមគ្រូពេទ្យក៏បានសែងបុរសម្នាក់នោះចេញពីឡានពេទ្យ
អញ្ចឹងដោយសារតែនៅក្នុងឡានពេទ្យអត់មានឧបករណ៍សង្គ្រោះគ្រប់គ្រាន់នោះទេ
ដូច្នេះគេត្រូវសែងបុរសម្នាក់នោះចេញពីឡានពេទ្យ ដោយដាក់នៅលើគ្រែរុញមួយ
អញ្ចឹងគេដាក់គាត់នៅលើគ្រែរុញ ហើយមានអ្នកគ្រូពេទ្យម្នាក់ គាត់រុញគ្រែ
រុញគ្រែរបស់បុរសនោះចូលទៅក្នុងបន្ទប់ព្យាបាល
អញ្ចឹងយើងឃើញអម្បាញ់មិញនៅពេលដែលទៅជួយសង្គ្រោះនៅកន្លែងកើតហេតុ
គ្រូពេទ្យគឺជាមនុស្សប្រុស ក៏ប៉ុន្តែនៅពេលដែលមកដល់មន្ទីរពេទ្យ យើងឃើញថាមានអ្នកគ្រូពេទ្យស្រី
អ្នកគ្រូពេទ្យស្រី ដើម្បីចាំជួយព្យាបាល អញ្ចឹងគាត់បានដាក់ឲ្យបុរសម្នាក់នោះគេងទៅលើគ្រែរុញមួយ
សែងបុរសម្នាក់នោះគឿឲ្យគេងទៅលើគ្រែរុញ
ហើយអ្នកគ្រូពេទ្យស្រីនោះបានរុញបុរសម្នាក់នោះចូលទៅក្នុងបន្ទប់ ដើម្បីជួយសង្គ្រោះ
ឬក៏ដើម្បីព្យាបាល អញ្ចឹងដោយសារតែបុរសម្នាក់នោះគាត់ឈឺខ្លាំង ដូច្នេះគាត់អត់អាចដឹងខ្លួនបានទេ
គាត់អត់អាចដើរខ្លួនឯងបានទេ ដែលគាត់កំពុងតែឈឺជើងយ៉ាងខ្លាំង និងឈឺខ្លួនគាត់យ៉ាងខ្លាំង
ដោយសារតែគាត់ដួលម៉ូតូបោកទៅនឹងថ្នល់ ដោយសារតែគាត់ជិះម៉ូតូលឿនពេក។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ១១ រូបភាពទី ១១ បន្ទាប់ពីគាត់ចូលដល់បន្ទប់សង្គ្រោះបន្ទាន់ហើយ
អញ្ចឹងក្រុមគ្រូពេទ្យក៏ចាប់ផ្តើមចាក់ថ្នាំឲ្យគាត់ ដោយសារតែគាត់មានរបួស
ដូច្នេះអ្នកគ្រូពេទ្យក៏ចាប់ផ្តើមព្យួរសេរ៉ូម ដើម្បីបំបាត់ការឈឺចាប់
អញ្ចឹងយើងឃើញនៅក្នុងរូបភាពនេះ គឺយើងឃើញគ្រូពេទ្យកំពុងតែយកម្ជុលមកចាក់ដៃរបស់គាត់
អញ្ចឹងម្ជុលចាក់ថ្នាំគឺជាម្ជុលដែលតូចមួយ ដែលមានប្រឡោះ
ឬក៏ម្ជុលនោះគឺមានប្រហោងនៅខាងក្នុង ដើម្បីបង្ហូរថ្នាំចូលទៅក្នុងខ្លួន អញ្ចឹងម្ជុលពេលខ្លះ
គឺគេប្រើម្ជុលចាក់ថ្នាំ ប្រសិនបើយើងអត់សូវធ្ងន់ធ្ងរទេ គឺគ្រាន់តែយកម្ជុលឬយកសឺរ៉ាំង
សឺរ៉ាំងមកចាក់ថ្នាំយើងជាការស្រេច ក៏ប៉ុន្តែប្រសិនបើអ្នកខ្លះគាត់ធ្ងន់ធ្ងរ គឺគេត្រូវព្យួរសេរ៉ូម
អញ្ចឹងសេរ៉ូមគឺជាថុងទឹក ឬក៏ដបទឹកមួយ ដបទឹកថ្នាំមួយដប ដែលគេប្រើប្រាស់ទុយោ
ភ្ជាប់ជាមួយនឹងម្ជុលចាក់ថ្នាំដើម្បីបង្ហូរចូលទៅក្នុងខ្លួន អញ្ចឹងគេយកម្ជុលចាក់ចូលទៅក្នុងសរសៃយើង
ហើយបង្ហូរជាតិថ្នាំចូលទៅតាមម្ជុលនោះតិចៗ ព្រោះពេលខ្លះអ្នកជំងឺធ្ងន់ធ្ងរ គឺគេត្រូវប្រើសេរ៉ូម
ដើម្បីឲ្យអ្នកជំងឺនោះមានសភាពធម្មតាឡើងវិញ ក៏ប៉ុន្តែនៅពេលដែលអ្នកជំងឺធូរស្បើយហើយ
គេគ្រាន់តែប្រើម្ជុលចាក់ថ្នាំ ដោយប្រើសឺរ៉ាំងតូចៗតែប៉ុណ្ណោះ អញ្ចឹងដើម្បីព្យួរសេរ៉ូមបាន
នៅក្នុងរូបភាពនេះ គឺយើងឃើញគេចាក់ម្ជុលចូលទៅក្នុងដៃរបស់បុរសម្នាក់នោះហើយ
បន្ទាប់មកគាត់បានយកស្កុតមកបិទត្រង់មុខម្ជុលដើម្បីកុំឲ្យរបូត
ដោយសារតែសេរ៉ូមគឺត្រូវការរយៈពេលយូរ ដើម្បីឲ្យវាស្រក់អស់ចេញពីក្នុងដប
ដូច្នេះគ្រូពេទ្យត្រូវយកស្កុតមករុំមុខម្ជុល ដើម្បីកុំឲ្យរបូតចេញពីដៃ
ព្រោះពេលខ្លះប្រសិនបើរបូតចេញពីដៃ គឺពិបាកនៅក្នុងការដោតចូលវិញ
អញ្ចឹងគេត្រូវបិទយ៉ាងប្រុងប្រយ័ត្នបំផុត ដើម្បីកុំឲ្យសេរ៉ូមនោះរបូតចេញពីដៃ។

បន្ទាប់មកទៀតរូបភាពទី ១២ រូបភាពទី ១២ បុរសម្នាក់នោះ
គាត់ក៏បានបើកភ្នែកនៅពេលដែលក្រុមគ្រូពេទ្យគាត់បានព្យួរសេរ៉ូមហើយ
អញ្ចឹងនៅក្នុងរូបភាពនេះយើងឃើញគាត់កំពុងតែគេងនៅលើគ្រែពេទ្យ
ដោយគ្រែនោះគឺយើងអាចបត់បាន អញ្ចឹងយើងឃើញនៅជើង នៅផ្នែកខាងក្រោម
គឺយើងឃើញត្រង់ធម្មតា ប៉ុន្តែផ្នែកខាងលើចាប់ពីចង្កេះដល់ក្បាល
គឺយើងឃើញខ្ពស់ជាងខាងក្រោមបន្តិច គឺដើម្បីឲ្យគាត់ងាយស្រួលគេង
អញ្ចឹងគេធ្វើបែបនេះដើម្បីឲ្យគាត់ងាយស្រួលគេង
ហើយយើងឃើញគាត់ឈឺជើងរបស់គាត់យ៉ាងខ្លាំង ដោយសារតែគាត់ដួលបោកទៅនឹងថ្នល់
ហើយជើងរបស់គាត់បានប៉ះទង្គិចខ្លាំង ដូច្នេះគាត់ឈឺជើងយ៉ាងខ្លាំង
ហើយនៅក្បែរគ្រែរបស់គាត់គេងយើងឃើញមានទូរទស្សន៍ចំនួនមួយ
ដែលទូរទស្សន៍នោះគឺជាឧបករណ៍សម្រាប់វាស់ចង្វាក់បេះដូង អញ្ចឹងពេលខ្លះប្រសិនបើយើងធ្ងន់ធ្ងរ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អ្នកជំងឺនោះធ្ងន់ធ្ងរ គឺគេត្រូវវាស់ចង្វាក់បេះដូងជានិច្ច ព្រោះដើម្បីឲ្យប្រាកដថាអ្នកជំងឺនោះ គាត់ចង្វាក់បេះដូងរបស់គាត់នៅដើរ ដូច្នេះគាត់អាចនៅមានជីវិតរស់នៅ
ក៏ប៉ុន្តែពេលខ្លះប្រសិនបើចង្វាក់បេះដូងលែងដើរ ទូរទស្សន៍នោះក៏លែងលោតអំពីចង្វាក់បេះដូង អញ្ចឹងបានន័យថាអ្នកជំងឺអាចបាត់បង់ជីវិត ឬក៏អាចស្លាប់បាន។
ដូច្នេះហើយនៅពេលដែលសង្គ្រោះបន្ទាន់ ក្រុមគ្រូពេទ្យតែងតែវាស់ចង្វាក់បេះដូងរបស់អ្នកជំងឺជានិច្ច ដើម្បីឲ្យប្រាកដថាអ្នកជំងឺគឺនៅរស់ ហើយយើងឃើញនៅក្បែរជាប់គ្រែរបស់គាត់គឺជាបង្គោលមួយ បង្គោលនោះគឺសម្រាប់ព្យួរដបសេរ៉ូម បានន័យថាគាត់កំពុងតែព្យួរសេរ៉ូម ដើម្បីបំបាត់ការឈឺចាប់ អញ្ចឹងសេរ៉ូមនេះអាចជាសេរ៉ូមថ្នាំស្ពឹក ឬក៏អាចជាសេរ៉ូមថ្នាំសន្លប់
ដោយសារតែគាត់មានគ្រោះថ្នាក់ចរាចរណ៍ ដូច្នេះពេលខ្លះពេទ្យគាត់អាចធ្វើការវះកាត់ អញ្ចឹងដើម្បីកុំឲ្យមានការឈឺចាប់នៅពេលការវះកាត់ គេអាចប្រើប្រាស់ថ្នាំស្ពឹក គឺថ្នាំម្យ៉ាងដែលធ្វើឲ្យយើងលែងមានអារម្មណ៍ថាឈឺ
បានន័យថានៅពេលដែលយើងចាក់ថ្នាំស្ពឹកហើយ គឺកន្លែងដែលយើងចាក់ថ្នាំ គឺលែងមានអារម្មណ៍ថាឈឺ ទោះបីជាគេយកកាំបិត ឬក៏ម្ជុលមកវះ ឬក៏កាំបិតមកវះក៏ដោយ គឺយើងអត់មានអារម្មណ៍ថាឈឺដែរ។ ប៉ុន្តែប្រសិនបើធ្ងន់ធ្ងរ ឬក៏គាត់ការវះកាត់នោះធំ គឺគេត្រូវប្រើថ្នាំសន្លប់ អញ្ចឹងនៅពេលដែលយើងត្រូវថ្នាំសន្លប់ គឺយើងសន្លប់អត់ដឹងខ្លួនទេ ដូច្នេះគេអាចធ្វើការវះកាត់បានដោយយើងអត់សូវឈឺ ដោយយើងអត់ដឹងខ្លួនថាឈឺនោះទេ។

បន្ទាប់មកទៀតរូបភាពទី ១៣ នៅក្នុងរូបភាពទី ១៣ ដោយសារតែបុរសម្នាក់នោះ គាត់មានអាការៈធ្ងន់ធ្ងរនៅនឹងជើងរបស់គាត់ ដោយសារតែគាត់ប៉ះទង្គិចធ្ងន់ធ្ងរ ដោយសារតែជើងរបស់គាត់ត្រូវប៉ះទង្គិចធ្ងន់ធ្ងរ
ដូច្នេះក្រុមគ្រូពេទ្យក៏បានព្យួរសេរ៉ូមថ្នាំសន្លប់ឲ្យគាត់។ អញ្ចឹងបុរសម្នាក់នោះ គាត់ក៏បានសន្លប់នៅពេលដែលគាត់ត្រូវសេរ៉ូមថ្នាំសន្លប់នោះ។
ដូច្នេះហើយក្រុមគ្រូពេទ្យក៏ចាប់ផ្តើមធ្វើការវះកាត់ជើងរបស់គាត់ អញ្ចឹងនៅក្នុងរូបភាពទី ១៣ នេះ យើងឃើញបុរសម្នាក់នោះ គាត់ក៏បានសន្លប់ ក៏ប៉ុន្តែដៃរបស់គាត់នៅតែព្យួរសេរ៉ូមដដែល ព្រោះដើម្បីឲ្យប្រាកដថា ការវះកាត់ជោគជ័យ បុរសម្នាក់នោះនៅមិនទាន់ដឹងខ្លួន ដូច្នេះគឺគេត្រូវដាក់ថ្នាំសេរ៉ូមសន្លប់ឲ្យគាត់នៅពេលដែលគេកំពុងតែវះកាត់ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញគ្រូពេទ្យម្នាក់ គាត់កំពុងតែកាន់កាំបិតនិងកន្ត្រៃ
ហើយវះកាត់ជើងបុរសម្នាក់នោះកន្លែងដែលមានរបួស អញ្ចឹងមាន ការវះកាត់គឺមានគ្រូពេទ្យចំនួនពីរ ដែលគ្រូពេទ្យមួយទៀតគឺជាជំនួយការ
អញ្ចឹងជំនួយការគ្រូពេទ្យតែងតែកាន់ឧបករណ៍នៅក្បែរគ្រូពេទ្យជានិច្ច ដើម្បីយកឧបករណ៍ដែលគ្រូពេទ្យត្រូវការយកមកឲ្យលោកគ្រូពេទ្យធ្វើការវះកាត់ជើង

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងនៅក្នុងនេះ គឺយើងឃើញម៉ូនីទ័រឬក៏អេក្រង់ទូរទស្សន៍នោះ
កំពុងតែលោតចង្វាក់បេះដូងរបស់បុរសម្នាក់នោះ ដោយសារតែគេដាក់ថ្នាំសន្លប់ឲ្យគាត់
ដូច្នេះក្រុមគ្រូពេទ្យត្រូវការវាស់ចង្វាក់បេះដូងរបស់បុរសម្នាក់នោះជានិច្ច
ដើម្បីឲ្យប្រាកដថាគាត់អាចនៅដឹងខ្លួននៅឡើយ គាត់មិនទាន់បាត់បង់ជីវិត
អញ្ចឹងគាត់ធ្វើការវះកាត់ជើងរបស់បុរសម្នាក់នោះ ដើម្បីយកកម្ទេចកម្ទីចេញ
ឬក៏ដើម្បីធ្វើការព្យាបាលឆ្អឹងរបស់គាត់ដែលបានបាក់ បន្ទាប់ពីការវះកាត់ហើយ
គឺក្រុមគ្រូពេទ្យត្រូវការដេរផ្ចិតមុខរបួសឡើងវិញ អញ្ចឹងដើម្បីកុំឲ្យបុរសម្នាក់នោះមានការឈឺចាប់
នៅពេលដែល ក្នុងការវះកាត់ក៏ដូចជានៅក្នុងពេលដែលដេរមុខរបួសនោះឲ្យជិតវិញ
ដូច្នេះបុរសម្នាក់នោះត្រូវបានគេដាក់ថ្នាំសន្លប់នៅក្នុងសេរ៉ូមរបស់គាត់ អញ្ចឹងនៅក្នុងរូបភាពនេះ
គឺបុរសម្នាក់នោះ គាត់សន្លប់អត់ដឹងខ្លួនទេ
បានន័យថាអត់ដឹងថាក្រុមគ្រូពេទ្យកំពុងតែធ្វើការវះកាត់នោះទេ។

បន្ទាប់មកទៀតរូបភាពទី [១៤] នៅក្នុងរូបភាពទី [១៤] យើងឃើញថា
បន្ទាប់ពីបុរសម្នាក់នោះវះកាត់រួចរាល់ហើយ អញ្ចឹងបុរសម្នាក់នោះ
គាត់បានវះកាត់ជើងរបស់គាត់រួចរាល់ហើយ
ដូច្នេះក្រុមគ្រូពេទ្យក៏បានយកគាត់មកសម្រាកនៅក្នុងបន្ទប់អ្នកជំងឺធម្មតាវិញ
អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញបុរសម្នាក់នោះ គាត់កំពុងតែគេងនៅលើគ្រែពេទ្យ
ដោយយើងឃើញខ្នងរបស់គាត់គឺផ្អែកទៅនឹងខ្នើយ ទៅនឹងគ្រែពេទ្យដែលគេលើកឡើងខ្ពស់
ហើយជើងរបស់គាត់រុំទៅនឹងប៉ង់មួយ អញ្ចឹងដោយសារតែជើងរបស់គាត់មានរបួសបាក់ឆ្អឹង
ដូច្នេះពេទ្យត្រូវការបិទស៊ីម៉ងត៍ គាត់បិទស៊ីម៉ងត៍ហើយគាត់រុំនឹងប៉ង់ ដើម្បីឲ្យជើងរបស់គាត់ត្រង់
មិនអាចកម្រើកបាន ព្រោះជើងដែលមានរបួសគឺយើងអត់អាចកម្រើកនោះទេ ប្រសិនបើកម្រើក
ប្រសិនបើកម្រើកវាអាចធ្វើឲ្យមិនងាយនឹងជា បានន័យថាវាធ្វើឲ្យយើងយូរនឹងជា ដូច្នេះ
ឬក៏អាចធ្វើឲ្យមុខរបួសកាន់តែធ្ងន់ធ្ងរ អញ្ចឹងពេទ្យក៏បានប្រើប្រាស់របស់រឹង
ដើម្បីរុំឬក៏អបជើងរបស់បុរសម្នាក់នោះកុំឲ្យកម្រើក ហើយលើកជើងបុរសម្នាក់នោះយួរឡើងលើ
អញ្ចឹងគាត់បានយកប៉ង់ដើម្បីយួរជើងបុរសនោះឡើងលើ ដើម្បីកុំឲ្យកម្រើក
ដើម្បីឲ្យបុរសម្នាក់នោះឆាប់ជា ហើយយើងឃើញនៅចុងគ្រែរបស់គាត់
គឺយើងឃើញមានមនុស្សចាស់ចំនួនពីរនាក់ ដែលមនុស្សចាស់ទាំងពីរនាក់នោះអាយុគាត់ប្រហែលជា
៦០ ឆ្នាំ ដែលម្នាក់គឺជាស្ត្រី និងម្នាក់ទៀតគឺជាបុរស ដែលមនុស្សចាស់ទាំងពីរនាក់នោះ
ប្រហែលជាឪពុកម្តាយរបស់គាត់ ដែលបានមកសួរសុខទុក្ខគាត់
អញ្ចឹងជាទូទៅនៅពេលដែលមានអ្នកជំងឺនៅមន្ទីរពេទ្យ
គឺយើងតែងតែមានសាច់ញាតិមកសួរសុខទុក្ខជានិច្ច ដោយជាក់ស្តែងនៅក្នុងរូបភាពនេះ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺឪពុកម្ដាយរបស់គាត់បានមកសួរសុខទុក្ខគាត់នៅក្នុងមន្ទីរពេទ្យ
ដើម្បីចង់ដឹងអាការៈរបស់គាត់តើបានធូរស្បើយហើយឬនៅ។

បន្ទាប់មកទៀតរូបភាពទី ១៥ រូបភាពទី ១៥
ក្រោយពេលចូលសម្រាកនៅក្នុងមន្ទីរពេទ្យបានមួយរយៈ ក្រោយមកយើងឃើញបុរសម្នាក់នោះ
គាត់ក៏ចាប់ផ្ដើមរៀនដើរឡើងវិញ ប៉ុន្តែដោយសារតែជើងរបស់គាត់អត់ទាន់ជាស្រួលបួល
អញ្ចឹងជើងរបស់គាត់អត់ទាន់ជាស្រួលបួលនោះទេ
ដូច្នេះការរៀនដើររបស់គាត់គឺត្រូវពឹងផ្អែកទៅលើឈើច្រត់
ដោយយើងឃើញនៅក្នុងរូបភាពនេះឪពុកម្ដាយរបស់គាត់ជួយទប់គាត់សងខាង
គឺនៅឆ្វេងមួយនិងនៅស្ដាំមួយ ដោយឪពុករបស់គាត់គឺឈរនៅខាងឆ្វេង
និងម្ដាយរបស់គាត់ឈរទប់គាត់នៅខាងស្ដាំ ចំណែកឯគាត់ ដៃទាំងសងខាងរបស់គាត់
គឺកាន់ឈើច្រត់ចំនួនពីរ ហើយគាត់កំពុងតែរៀនដើរនៅតាមផ្លូវ
ដើម្បីឲ្យជើងរបស់គាត់ស៊ាំទៅនឹងការដើរឡើងវិញ។ ព្រោះដោយសារតែជើងរបស់គាត់បាក់
ដូច្នេះពិបាកនៅក្នុងការដើរណាស់ នៅពេលដែលគាត់ជាភ្លាមៗ
អញ្ចឹងហើយគាត់ត្រូវការប្រើប្រាស់ឈើច្រត់ដើម្បីជាជំនួយនៅក្នុងការដើរ។

បន្ទាប់មកទៀតរូបភាពទី ១៦ នៅក្នុងរូបភាពទី ១៦ យើងឃើញថា បន្ទាប់ពីបុរសម្នាក់នោះ
គាត់ព្យាបាលបានជាសះស្បើយហើយ គាត់ក៏បានយកវិក្កយបត្រពេទ្យដើម្បីមកមើល អញ្ចឹងជាទូទៅ
ពេលខ្លះពេទ្យនៅក្នុងប្រទេសកម្ពុជា គឺប្រសិនបើយើងទៅគេងនៅក្នុងពេទ្យធំៗគឺមានតម្លៃថ្លៃ
ចំណែកឯពេទ្យតូចៗគឺមានតម្លៃថោក ហើយសម្រាប់ការព្យាបាលគឺពឹងផ្អែកទៅលើការព្យាបាល
អញ្ចឹងប្រសិនបើយើងគេងនៅក្នុងពេទ្យយូរ គឺការព្យាបាលគឺអស់ថ្លៃ
ប៉ុន្តែប្រសិនបើយើងគេងពេទ្យត្រឹមតែមួយថ្ងៃឬក៏ពីរថ្ងៃ យើងអាចចំណាយអស់ត្រឹមតែពី ១០០
ដុល្លារទៅ ៣០០ ដុល្លារតែប៉ុណ្ណោះ ក៏ប៉ុន្តែប្រសិនបើយើងគេងពេទ្យរយៈពេលយូរ
យើងអាចចំណាយអស់ពី ៥០០ ទៅដល់ ១០០០ ដុល្លារ ឬក៏អាចលើសនេះ
ព្រោះដោយសារតែតម្លៃទៅតាមពេទ្យ ពេទ្យធំនិងពេទ្យតូច
អញ្ចឹងប៉ុន្តែពេលខ្លះគឺយើងអាចប្រើប្រាស់ធានារ៉ាប់រង សេវាធានារ៉ាប់រងរបស់ក្រុមហ៊ុនមួយចំនួន
អញ្ចឹងប៉ុន្តែភាគច្រើននៅក្នុងប្រទេសកម្ពុជា
ប្រជាជនកម្ពុជាគាត់អត់សូវប្រើប្រាស់សេវាធានារ៉ាប់រងនោះទេ អញ្ចឹងនៅពេលដែលគាត់មានជំងឺ
ឬក៏នៅពេលដែលគាត់មានគ្រោះថ្នាក់ ហើយទៅព្យាបាលនៅមន្ទីរពេទ្យ គឺគាត់ចេញលុយខ្លួនឯង
បានន័យថាគាត់ចំណាយលុយផ្ទាល់ខ្លួន ប៉ុន្តែសម្រាប់អ្នកដែលគាត់ប្រើប្រាស់សេវាធានារ៉ាប់រង
គឺគាត់អត់ចាំបាច់ចេញលុយ ឬក៏ចំណាយលុយផ្ទាល់ខ្លួននោះទេ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺក្រុមហ៊ុនធានារ៉ាប់រងនឹងទទួលរ៉ាប់រងនូវការចំណាយព្យាបាលរបស់គាត់ទាំងស្រុង
ដោយគាត់គ្រាន់តែបង់សេវាប្រចាំឆ្នាំទៅឲ្យក្រុមហ៊ុនធានារ៉ាប់រងតែប៉ុណ្ណោះ
ហើយក្រុមហ៊ុនធានារ៉ាប់រងគឺយើងអាចធានារ៉ាប់រងនៅពេលដែលយើងមានគ្រោះថ្នាក់
ឬក៏នៅពេលដែលយើងមានជំងឺបាន ដោយការធានារ៉ាប់រងនោះ ពេលខ្លះ ក្រុមហ៊ុនខ្លះ
គឺគាត់ធានារ៉ាប់រង ២៤ ម៉ោងគ្រប់ទីកន្លែងទាំងអស់ អញ្ចឹងនៅពេលដែលយើងមានជំងឺ
ឬក៏នៅពេលដែលយើងគ្រោះថ្នាក់ យើងគ្រាន់តែទៅមន្ទីរពេទ្យ
នោះក្រុមហ៊ុនធានារ៉ាប់រងនឹងចេញថ្លៃសេវាថ្នាំពេទ្យ ហើយនិងថ្លៃព្យាបាលឲ្យយើងទាំងអស់
ក៏ប៉ុន្តែប្រសិនបើយើងអត់មានធានារ៉ាប់រងទេ គឺយើងត្រូវចំណាយប្រាក់ផ្ទាល់ខ្លួន
ដើម្បីព្យាបាលជំងឺរបស់យើង ដែលជាក់ស្តែងបុរសម្នាក់នេះ
ប្រហែលជាគាត់អត់មានសេវាធានារ៉ាប់រងទេ បានន័យថាគាត់អត់បានទិញសេវាធានារ៉ាប់រងទេ
ដូច្នេះនៅពេលដែលគាត់កាន់វិក្កយបត្រពេទ្យមក គឺគាត់ភ្ញាក់ផ្អើលយ៉ាងខ្លាំង ប្រហែលជាអស់ច្រើន
បានន័យថាដោយសារតែគាត់បាក់ជើងនិងនៅពេទ្យយូរ ដូច្នេះការចំណាយរបស់គាត់គឺអស់ច្រើន
អញ្ចឹងហើយទើបគាត់មើលទៅក្នុងវិក្កយបត្រពេទ្យបណ្តើរ គាត់មានអាការៈភ្ញាក់ផ្អើលបណ្តើរ
ដោយសារតែឃើញតម្លៃថ្លៃពេក ដោយសារតែឃើញវិក្កយបត្រនោះគឺមានតម្លៃថ្លៃពេក។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.